# សាធារណរដ្ឋប្រជាមានិតកម្ពុជា

ក្រុមប្រឹក្សារដ្ឋ

លេខ ២៥ ក្រ-ច

## ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

# ក្រឹត្យ-ច្បាប់

## ស្តីពី

## របបជីវភាពនៃទណ្ឌិត និង ជនឃុំខ្លួនបណ្តោះអាសន្ន

# ក្រុមប្រឹក្សារដ្ឋ

## នៃ សាធារណរដ្ឋប្រជាមានិតកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា

-បានឃើញច្បាប់ ស្តីពីការរៀបចំរដ្ឋសភា និង ក្រុមប្រឹក្សារដ្ឋ ដែលប្រកាសឲ្យប្រើដោយក្រឹត្យលេខ០៤ ក្រ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៨២

-បានឃើញច្បាប់ស្តីអំពីអង្គការចាត់តាំង និង សកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ០៣ ក្រ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៨២

-បានឃើញក្រឹត្យ-ច្បាប់ លេខ០៧ ក្រ.ច ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៨២ ស្តីពីសមត្ថកិច្ច និង នីតិវិធីនៃការធ្វើច្បាប់ និង បទបញ្ជា

-តាមសំណើរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី

<u>សម្រេច</u>

មាត្រា១ -ទណ្ឌិត និង ជនដែលត្រូវឃុំខ្លួនជាបណ្តោះអាសន្ននៅពន្ធនាគារ មន្ទីរកែប្រែ និងមន្ទីរឃុំឃាំងផ្សេងៗក្នុងសាធារណរដ្ឋប្រជាមានិតកម្ពុជា និងកូនទណ្ឌិត និងពិរុទ្ធជនដែលមានអាយុតិចជាង០៣ឆ្នាំ មិនអាចបំបែកចេញពីម្តាយបានត្រូវបានទទួលរបបហូបចុក ស្លៀកពាក់ ថែរក្សាសុខភាព និង សម្ភារៈប្រើប្រាស់ចាំបាច់ផ្សេងៗ សម្រាប់ជីវភាពរស់នៅ ។

មាត្រា ២ -ប្រាក់ចំណាយផ្សេងៗ សម្រាប់របបនេះត្រូវជាបន្ទុក នៃថវិការដ្ឋ ។

មាត្រា ៣ -ក្រុមប្រឹក្សារដ្ឋមន្ត្រី នឹងកំណត់តាមអនុក្រឹត្យនូវរបបដែលត្រូវឧបត្ថម្ភ និងបែបបទសម្រាប់អនុវត្តក្រឹត្យ-ច្បាប់នេះ ។

មាត្រា ៤ -ក្រឹត្យ-ច្បាប់នេះមានអានុភាពគតិយុត្តិចាប់ពីថ្ងៃប្រកាសផ្សាយជាសាធារណៈ ។

ធ្វើភ្នំពេញ, ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៨៥

ជ-ក្រុមប្រឹក្សារដ្ឋ

ប្រធាន

ហត្ថលេខ និងត្រា

**ហេង សំរិន**

ទទួលបន្ទុកអនុវត្ត

ប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

ដើម្បីចម្លងចែក

អគ្គលេខាធិការក្រុមប្រឹក្សារដ្ឋ

ហត្ថលេខា និងត្រា

**ចាន ប៉ែន**